# សិទ្ធិអ្នកនិពន្ធ

Copy Rights

# សេចក្ដីផ្ដើម

- សិទ្ធិអ្នកនិពន្ធ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិ ទាំងឡាយនៃកម្មសិទ្ធិបញ្ញា ដែលអ្នកនិពន្ធបាន បង្កើតឡើងនៅក្នុងការតែងនិពន្ធផ្សេងៗ គំនូរ ស្នាដៃស្ថាបត្យកម្ម និងស្នាដៃជាច្រើនទៀត។

- សិទ្ធិអ្នកនិពន្ធជាសិទ្ធិតាមផ្លូវច្បាប់ដល់ ដែលផ្ដល់ឲ្យអ្នកនិពន្ធ សិល្បៈករ ឬអ្នកបង្កើតស្នាដៃផ្សេងៗទៀត ក្នុងការប្រើប្រាស់និងការពារស្នាដៃរបស់ខ្លួន។

# សេចក្តីផ្តើម

- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ការពារនូវផលិតផលវប្បធម៌ដែលជាស្នាដៃរបស់អ្នកនិពន្ធ អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ធានាការធ្វើអាជីវកម្មស្របច្បាប់ លើផលិតផលវប្បធម៌ទាំងនេះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ និងសេដ្ឋកិច្ចជាតិ។

# និយមន័យ

- **ស្នាដៃ** ជាផលិតផលខាងវិស័យអក្សរសាស្រ្ត វិទ្យាសាស្រ្ត សិល្បៈ ឬ តូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា។

- **អ្នកនិពន្ធ** ជាជនដែលបង្កើតស្នាដៃ

- **ការសម្តែង** ជាការបញ្ចេញស្នាដៃលើឆាក ដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬ បង្ហាញតាមមធ្យោបាយ និងវិធីសផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្រ្ត ការអប់រំ ឬ វិទ្យាសាស្រ្ត

# និយមន័យ

- **ការសូត្រ** ជាការបញ្ចូលសម្លេងដោយការនិយាយ ការអាន និងការសូត្រនូវស្នាដៃផ្សេងៗ
- **អ្នកសម្តែង** ជាសិល្បៈករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជនដែលធ្វើការសម្តែង
- **ប្រព័ន្ធទិន្នន័យ** ជាសំណុំព័ត៌មាន អត្ថបទ លេខ ឌីយ៉ា-ក្រាម ដែលបង្កើត និងស្រាវជ្រាវដោយប្រព័ន្ធកុំព្យូទ័រ

# និយមន័យ

- **ស្លាដៃសោតទស្សន៍** ជាស្នាដៃដែលបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឲ្យមើលឃើញបានទោះបីមាន ឬពុំមានបញ្ជូលសម្លេង ហើយបើមានបញ្ជូលសម្លេង គឺអាចស្តាប់ឮសូរសម្លេងបាន។
- **ទូផ្សាយ** ជាការផ្សាយសម្លេង រូបភាព ឯកសារ ឬ សារនានាគ្រប់ប្រភេទតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប។

# និយមន័យ

- **ការផ្សព្វផ្សាយជាសាធារណៈ** ជាការផ្សាយតាមខ្សែ ឬគ្មានខ្សែក្រៅរង្វង់គ្រួសារនូវរូបភាព ឬសម្លេង ឬរូបភាពជាមួយសម្លេងនៃស្នាដៃណាមួយដែលអាចឲ្យសាធារណជនទទួលបាននៅទីកន្លែងដើម ឬទីកន្លែងដទៃទៀត ដោយមិនគិតថា ជននោះទទួល ឬមិនទទួលនូវរូបភាព ឬសម្លេងនោះក្នុងពេល និងទីកន្លែងជាមួយគ្នា ឬក្នុងពេល និងទីកន្លែងខុសគ្នា តាមការជ្រើសរើសផ្ទាល់ខ្លួនរបស់គេ។

# និយមន័យ

- **ហ្វូណូក្រាម** ជាវត្ថុដែលបានថតបញ្ចូលសម្លេង នៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសម្លេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗ ទៀត។
- **ផលិតករហ្វូណូក្រាម** ជាជនដែលបានផលិតហ្វូណូក្រាម
- **កម្មវិធីកុំព្យូទ័រ** ជាសំណុំនៃសេចក្តីណែនាំដែលធ្វើឡើងតាមអក្សរ ឬលេខកូដ ឬគំនូរបំព្រួញ ឬតាមទម្រង់ណាមួយ ជាហេតុធ្វើឲ្យគេបំពេញបាន ឬទទួលបាននូវកិច្ចការ ឬលទ្ធផលពិសេសណាមួយតាមមធ្យោបាយកុំព្យូទ័រ ឬ តាមវិធីសាស្រ្តអេឡិចត្រូនិច ដើម្បីបម្រើកិច្ចការព័ត៌មានបាន កាលណាកម្មវិធីនោះត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ។

# និយមន័យ

- **ការផលិតឡើងវិញ** ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់តាមមធ្យោបាយ ឬទម្រង់ណាមួយ គតិបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាមដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្ន តាមទម្រង់អេឡិចត្រូនិច។
- **អង្គភាពផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទុរទស្សខ្សែកាប ឬផ្កាយរណប។
- **សិទ្ធិប្រហាក់ប្រហែល** ជាសិទ្ធិអ្នកសម្តែង សិទ្ធិផលិតករ ហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ។

# ស្លាកដែលអាចការពារតាមច្បាប់កម្ពុជា

**១.ស្លាកសញ្ញានិពន្ធ** ( ម. ៣.១ )៖

១.១. ស្លាកសញ្ញាដែលបង្កើតឡើងដោយជនជាតិខ្មែរ ឬជនដែលមានលំនៅក្នុងប្រទេសកម្ពុជា (រួមទាំងនីតិបុគ្គល) ដោយគោរពតាមច្បាប់កម្ពុជា និងមានការិយាល័យនៅក្នុងប្រទេសកម្ពុជា។

# ស្លាកសញ្ញាដែលអាចការពារតាមច្បាប់កម្ពុជា

**១. ស្លាកសញ្ញាអ្នកនិពន្ធ (ម. ៣.១)៖**

១.២. ស្លាកសញ្ញាដែលបានបោះពុម្ព លើកដំបូងក្នុងប្រទេសកម្ពុជា ឬ ដែលបានបោះពុម្ពលើកដំបូងនៅបរទេស ហើយបានយកមកបោះពុម្ពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុង**អំឡុង ៣០ថ្ងៃ។**

១.៣. ស្លាកសញ្ញាសោតទស្សន៍ ដែលផលិតកម្មមានទីលំនៅ ឬ ស្នាក់ការនៅកម្ពុជា។

# ស្នាដៃដែលអាចការពារតាមច្បាប់កម្ពុជា

**១. ស្នាដៃអ្នកនិពន្ធ ( ម. ៣.១ )៖**

១.៤.	ស្នាដៃស្ថាបត្យកម្មដែលបានសាងសង់នៅកម្ពុជា និងស្នាដៃសិល្បៈផ្សេងៗ ដែលភ្ជាប់ទៅនឹងអគារ ឬ រចនាសម្ព័ន្ធផ្សេងទៀត។

១.៥.	ស្នាដៃដែលកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងអន្តរជាតិ។

# ស្លាកដែលអាចការពារតាមច្បាប់កម្ពុជា

## ២. ស្លាកអ្នកសម្ដែង (ម ៣(២))៖

២.១. ស្លាកដែរបស់អ្នកសម្ដែងដែលមានសញ្ជាតិខ្មែរ។

២.២. ស្លាកដែរបស់អ្នកសម្ដែងដែលពុំមានសញ្ជាតិខ្មែរ តែការសម្ដែងនោះ:

- បានប្រព្រឹត្តឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បានថតបញ្ចូលជាហ្វូណូក្រាម
- ពុំទាន់បានថតបញ្ចូលជាហ្វូណូក្រាម ប៉ុន្តែបានផ្សព្វផ្សាយតាមទូរផ្សាយ

# ស្លាកសញ្ញាដែលអាចការពារតាមច្បាប់កម្ពុជា

**៣- ហ្វូណ្ឌក្រោមគឺ ( ម ៣( ៣ ) )៖**

៣.១. ហ្វូណ្ឌក្រោមរបស់ផលិតករមានសញ្ជាតិខ្មែរ

៣.២. ហ្វូណ្ឌក្រោមដែលបានថតបញ្ចូលសូរសម្លេងជាលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣.៣. ហ្វូណ្ឌក្រោមដែលបានថតបញ្ចូលផ្សាយលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ស្លាកសញ្ញាដែលអាចការពារតាមច្បាប់កម្ពុជា

**៤. ការផ្សាយតាមទូរផ្សាយគឺ** (ម ៣(៤))៖

៤.១. ការផ្សាយនៃអង្គភាពទូរផ្សាយដែលមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤.២. ការផ្សាយចេញពីឧបករណ៍ផ្សាយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ស្នាដៃបន្ត

- ស្នាដៃបន្តរួមមាន ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអរស្នាដៃផ្សេងទៀត ឬការចងក្រងប្រព័ន្ធទិន្នន័យ ទោះបីជាក្នុងម៉ាស៊ីនដែលអាចអានបាន ឬក៏ជាទម្រង់ផ្សេងទៀត។
- កិច្ចការពារស្នាដៃណាមួយដែលបានលើកឡើងខាងលើ មិនធ្វើឱ្យបាត់បង់សិទ្ធិចំពោះកិច្ចការពារស្នាដៃដើមដែលត្រូវបានបញ្ចូល ឬ ប្រើប្រាស់សម្រាប់បង្កើតស្នាដៃថ្មី។

# ស្នាដៃសហការ

ជាស្នាដៃដែលមានរូបវន្តបុគ្គលច្រើននាក់ ចូលរួមសហការគ្នាដើម្បីបង្កើតនូវស្នាដៃនោះ (ម ៦ (១))។

# ស្នាដៃសមូហភាព

គឺជាស្នាដៃបង្កើតឡើងដោយរូបវន្តបុគ្គលច្រើននាក់ តាមគំនិតរបស់រូបវន្តបុគ្គលម្នាក់ ដែលបានធ្វើការបោះពុម្ពផ្សាយក្រោមការដឹកនាំ និងក្នុងនាមបុគ្គលនោះ (ម ៦(២))។

# ស្នាដៃដែលទទួលបានការការពារ

១. សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀត ស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ

២. អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយការនិយាយ ឬដោយការសរសេរ និងស្នាដៃផ្សេងទៀតដែលមានប្រភេទដូចគ្នា

៣. ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី

# ស្នាដៃដែលទទួលបានការការពារ

៤. ស្នាដៃរបាំសម័យ ឬការយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី

៥. ការសម្តែងសៀក និងការសម្តែងកាយវិការ

៦. ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង

៧. ស្នាដៃសោតទស្សន៍

៨. ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូន្យរូប ឬសិល្បៈអនុវត្ត

# ស្នាដៃដែលទទួលបានការការពារ

៩. ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប

១០. ស្នាដៃស្ថាបត្យកម្ម

១១. ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្ដែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា

# ស្លាកដែលទទួលបានការការពារ

១២. កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ

១៣. ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ (មាត្រា៧)

# សិទ្ធិអ្នកនិពន្ធស្នាដៃ

- សិទ្ធិបេតកភ័ណ្ឌ
- សិទ្ធិសីលធម៌

# ១. សិទ្ធិបេតកភ័ណ្ឌ

សិទ្ធិបេតិកភណ្ឌ ជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត។

# ១. សិទ្ធិបេតកភ័ណ្ឌ (ម ២១)(គ)

អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខធ្វើដោយខ្លួនឯង ឬអនុញ្ញាតឱ្យគេធ្វើកិច្ចការដូចតទៅ:

ក- ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួន។

ខ- ការយកលំនាំតាម ឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ។

គ- ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃ សោតទស្សន៍ ឬស្នាដៃថត បញ្ចូលជា ហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង។

ឃ- ការចែកចាយជាសធារណៈតាមការលក់ ការជួល ឬតាមផ្សេងៗបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ។

# ១. សិទ្ធិបេតកភ័ណ្ឌ (២១)(ត)

ង- ការនាំចូលក្នុងប្រទេសនូវស្នាដៃចម្លងចេញពីស្នាដៃ របស់សមីខ្លួនដែលជាអ្នកនិពន្ធ។

ច- ការសម្តែងស្នាដៃជាសាធារណៈ។

ជ- ការផ្សាយស្នាដៃជាសាធារណៈ។

ឈ- ការផ្សាយស្នាដៃតាមទូរផ្សាយ។

ញ- ការផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀត។ សិទ្ធិដាក់ជួលក្នុងចំនុច គ មិនត្រូវអនុវត្តចំពោះការជួលកម្មវិធីកុំព្យូទ័រឡើយ ក្នុងករណីដែលកម្មវិធីកុំព្យូទ័រនោះ មិនមែនជាកម្មវត្ថុដ៏សំខាន់សម្រាប់ការដាក់ជួល។

# សិទ្ធិសីលធម៌ (ម ២០)

សិទ្ធិសីលធម៌របស់អ្នកនិពន្ធមានបីចំនុចដូចខាងក្រោមៈ

ក. អ្នកនិពន្ធមានសិទ្ធិផ្ដាច់មុខក្នុងការសម្រេចពីរបៀប និងពេលនៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយ។

ខ. អ្នកនិពន្ធមានសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន។

# សិទ្ធិសីលធម៌ (ម ២០)

គ.  អ្នកនិពន្ធមានសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារជាហេតុធ្វើឱ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់ខ្លួន។ សិទ្ធិសីលធម៌របស់អ្នកនិពន្ធគឺជាសិទ្ធិអចិន្ត្រៃយ៍មិនអាចលក់ដូរបាន មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាល។

# ការកម្រិតសិទ្ធិអ្នកនិពន្ធ (ម ២៥(១))

អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់បានចំពោះ

ក. ការសម្តែងស្នាដៃជាឯកជនដោយមិនគិតជាកម្រៃ ជាការសម្តែងក្នុងរង្វង់គ្រួសារ ឬញាតិមិត្ត។

ខ. ការរៀបចំទុកក្នុងបណ្ណាល័យនូវសំណៅស្នាដៃណាមួយ ដើម្បីរក្សាទុកឱ្យបានគង់វង្ស ឬដើម្បីទុកសម្រាប់ធ្វើការស្រាវជ្រាវ។

គ. ការប្រើប្រាស់ស្នាដៃសម្រាប់ការសិក្សាដោយគ្មានរកប្រាក់កម្រៃ។

ឃ. ការបកប្រែស្នាដៃពីភាសាខ្មែរទៅជាភាសាជនជាតិភាគតិច ឬបកប្រែពីភាសាជនជាតិភាគតិចមកជាភាសាខ្មែរ។

# ការកម្រិតសិទ្ធិអ្នកនិពន្ធ (ម ២៥(២))

ប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធ និងប្រភពនៃស្នាដៃ អ្នកនិពន្ធមិនអាចធ្វើការហាមឃាត់ ចំពោះកិច្ចការទាំងឡាយដូចជា:

- ការវិភាគ និងអាគតដ្ឋានខ្លីៗនៃស្នាដៃដែលបញ្ជាក់ពីការរិះគន់ សង្គ្រាមប៉ាកកា គរុកោសល្យ វិទ្យាសាស្ត្រ ឬពត៌មានស្តីពីស្នាដៃនោះ
- ការផ្សព្វផ្សាយទស្សនៈសារព័ត៌មាន

# ការកម្រិតសិទ្ធិអ្នកនិពន្ធ (ម ២៥(២))

- ការផ្សាយទាំងស្រុង ឬភាគខ្លះនៃសន្ទរកថានានា ដែលបានថ្លែងជាសាធារណៈក្នុងសារព័ត៌មាន ឬទូផ្សាយ
- ការគ្រាប់កំប្លែង ការគ្រាប់តាមគំរូ ឬគំនូរត្លុក ដោយផ្អែកតាមលំនាំដើមនៃស្នាដៃ។
- ការចម្លងរូបភាពស្នាដៃសិល្បៈក្រាហ្វិក ឬសិល្បៈសូន្យរូបដែលស្ថិតនៅទីកន្លែងសាធារណៈមួយ លើកលែងតែរូបភាពនោះ ត្រូវបានចាត់ទុកថាជាកម្មវត្ថុសំខាន់នៃការចម្លងបន្ត។

# ការការពារសិទ្ធិអ្នកនិពន្ធ

ច្បាប់ក៏អនុញ្ញាតឱ្យស្រង់អាគតដ្ឋាន ពីស្នាដៃណាមួយជាស្នាដៃដែលបានផ្សព្វផ្សាយត្រឹមត្រូវ បញ្ចូលក្នុងស្នាដៃមួយផ្សេងទៀត ដោយពុំចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធ និងពុំចាំបាច់បង់ប្រាក់កម្រៃ។ ការស្រង់អាគតដ្ឋាន ត្រូវបញ្ជាក់អំពីប្រភព និងឈ្មោះអ្នកនិពន្ធបើនៅក្នុងប្រភពនោះ មានឈ្មោះអ្នកនិពន្ធច្បាស់លាស់។

# រយៈពេលនៃកិច្ចការពារ

- រយៈពេលនៃការការពារសិទ្ធិបេតិកភណ្ឌ ត្រូវប្រព្រឹត្តទៅអស់មួយជីវិតរបស់អ្នកនិពន្ធ ព្រមទាំងប្រព្រឹត្តទៅ ៥០ឆ្នាំ ក្រោយមរណភាពរបស់អ្នកនិពន្ធនោះ (មាត្រា៣០.១)។

# រយៈពេលនៃកិច្ចការពារ

- ការការពារសិទ្ធិបេតិកភណ្ឌ លើស្នាដៃសហ-ការ ត្រូវប្រព្រឹត្តទៅអស់មួយជីវិតអ្នកនិពន្ធដែលរស់នៅចុងក្រោយគេ ព្រមទាំងប្រព្រឹត្តទៅរយៈពេល ៥០ឆ្នាំ ក្រោយមរណភាពរបស់អ្នកនិពន្ធចុងក្រោយគេនោះ (មាត្រា ៣០.២)។

# រយៈពេលនៃកិច្ចការពារ

- សិទ្ធិបេតិកភណ្ឌនៃស្នាដៃអានាមិក ឬស្នាដៃរហស្សនាម ត្រូវទទួលបានការការពារក្នុងរយៈពេល ៧៥ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិននៃឆ្នាំ ដែលស្នាដៃនោះបានបោះពុម្ពជាលើកដំបូង ដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ (មាត្រា ៣១.១)។

# រយៈពេលនៃកិច្ចការពារ

- ក្នុងករណីដែល ពុំមានការបោះពុម្ពជាលើកដំបូង ក្នុងរយៈពេល ៥០ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃ នោះកិច្ចការពារក្នុងរយៈពេល ១០០ឆ្នាំត្រូវបានគិត ចាប់ពីដំណាច់ឆ្នាំប្រក្រតិទិននៃឆ្នាំដែលស្នាដៃនោះ បានបង្កើត (មាត្រា ៣១.២)។

# រយៈពេលនៃកិច្ចការពារ

- សិទ្ធិបេតិកភណ្ឌនៃស្នាដៃសម្ញហាភាពឬស្នាដៃសោតទស្សន៍ ឬស្នាដៃបច្ចាមរណៈ ត្រូវទទួលបានកិច្ចការពាររយៈពេល ៧៥ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតិទិន នៃឆ្នាំដែលស្នាដៃនោះបានផ្សព្វផ្សាយលើកដំបូង(មាត្រា ៣១.៣)។

# រយៈពេលនៃកិច្ចការពារ

- ក្នុងករណីដែល ពុំមានការផ្សព្វផ្សាយក្នុងរយៈពេល ៥០ឆ្នាំ បន្ទាប់ពីពេលបង្កើតស្នាដៃ នោះកិច្ចការពារក្នុងរយៈពេល ១០០ឆ្នាំ ត្រូវបានគិត ចាប់ពីដំណាច់ឆ្នាំប្រក្រតិទិននៃឆ្នាំដែលស្នាដៃនោះ បានបង្កើត(មាត្រា ៣១.៣)។

# ចាត់ទុកជាបទល្មើស អំពើទាំងឡាយដូចជា៖ (មាត្រា ៦២)

១. ការផលិតឬ ការនាំចូលដើម្បីដាក់លក់ ឬជួលនូវឧបករណ៍ ឬ គ្រឿងមធ្យោបាយណាមួយដែលធ្វើឡើង ឬយកលំនាំតាម ក្នុងគោលបំណងធ្វើឲ្យរាំងស្ទះដំណើរការល្អនៃឧបករណ៍ ឬគ្រឿងមធ្យោបាយទូទៅ ឬកាត់បន្ថយចំនួនការផលិតឡើងវិញនៃស្នាដៃហ្វូណូក្រាម ឬការផ្សាយតាមទូរផ្សាយ ឬធ្វើឲ្យខូចគុណភាពនូវច្បាប់ចម្លង។

២. ការផលិតឬ ការនាំចូលដើម្បីដាក់លក់ ឬជួលនូវឧបករណ៍ ឬ គ្រឿងមធ្យោបាយណាមួយ ដែលនាំឲ្យបុគ្គលគ្មានសិទ្ធិទទួលបាននូវកម្មវិធីផ្សាយតាមសញ្ញា លេខកូដ ដែលផ្សាយតាមទូរផ្សាយ ឬផ្សាយជាសាធារណៈតាមវិធីផ្សេង រួមមានការផ្សាយតាមផ្កាយរណប។

# ចាត់ទុកជាបទល្មើស អំពើទាំងឡាយដូចជា៖ (មាត្រា ៦២)

៣. ការលុបចោល ឬការកែប្រែព័ត៌មានស្តីពីរបបសិទ្ធិ តាមទម្រង់អេឡិចត្រូនិច ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

៤. ការចែកចាយ ឬការនាំចូល ដើម្បីចែកចាយការផ្សាយតាមអង្គភាពទូរផ្សាយ ការផ្សាយជាសាធារណៈ ឬការដាក់ជូនជាសាធារណជននូវស្នាដៃ ឬការសម្តែង ឬហ្វូណូក្រាម ឬកម្មវិធីផ្សាយនៃអង្គភាពទូរផ្សាយ ដោយគ្មានការអនុញ្ញាត ហើយអ្នកប្រព្រឹត្តដឹងច្បាស់ថា ព័ត៌មានស្តីពីរបបសិទ្ធិ តាមទម្រង់អេឡិចត្រូនិច ជាព័ត៌មានដែលត្រូវគេលុបចោល ឬកែប្រែរួចហើយ។

# ទោសប្បញ្ញត្ត (មាត្រា ៦៤)

- បទល្មើនៃការផលិត ឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥លានរៀលទៅ ២៥លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ខែ ដល់ ១២ខែ។
- ការនាំចូល ឬនាំចេញនូវផលិតផលបានពីបទល្មើសដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២លានរៀល ទៅ១០លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ខែ ដល់ ១២ខែ។

# ទោសប្បញ្ញត្ត (មាត្រា ៦៤)

- បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១លានរៀលទៅ ៥លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១ខែ ដល់ ៣ខែ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត។

# ទោសប្បញ្ញត្តិ (មាត្រា ៦៥)

- ការផលិត ឬការផលិតឡើងវិញ ដោយពុំមានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥លានរៀលទៅ ២៥លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ខែ ដល់ ១២ខែ។

# ទោសប្បញ្ញត្ត (មាត្រា ៦៥)

- ការនាំចូល ឬការនាំចេញនូវហ្វូណូក្រាម កាសែ្សត ឬកាសែ្សតវីដេអូ ដោយគ្មានការយល់ព្រមពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២លានរៀល ទៅ ១០លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនា-គារ ពី ១ខែ ដល់ ៣ខែ។

# ទោសប្បញ្ញត្ត (មាត្រា ៦៥)

- ការចាក់ផ្សាយតាមទូរផ្សាយ ដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១លានរៀល ទៅ ១០លានរៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ពី ១ខែ ដល់ ៣ខែ។

# សូមអរគុណ

